សិក្ខាសាលានៅកម្ពុជា ខែមិនា ឆ្នាំ ២០១៤

# អំពើអនីត្យានុកូល (ទ្រឹស្តីនៃលក្ខខ័ណ្ឌ)

ថ្ងៃទី ១២ ខែមិនា ឆ្នាំ ២០១៤

ក្រសួងយុត្តិធម៌  ការិយាល័យស្រាវជ្រាវកិច្ចការរួមនីតិកម្ម

ផ្នែកទំនាក់ទំនងអន្តរជាតិ  សាស្ត្រាចារ្យ ៖ ម៉ូរិ តូម៉ូយ៉ា

# មាតិកានៃបទបង្ហាញ

1. មូលដ្ឋាននៃប្រព័ន្ធអំពើអនីត្យានុកូល
2. ការបំពានសិទ្ធិ និងភាពផ្ទុយច្បាប់
3. កំហុស
4. ការកើតឡើងនៃការខូចខាត
5. ទំនាក់ទំនងហេតុ និងផល
6. សំណួរ និង ចម្លើយ

# ១ មូលដ្ឋាននៃប្រព័ន្ធអំពើអនីត្យានុក្កូល

## ១.១ ប្រព័ន្ធនៃការទទួលខុសត្រូវរដ្ឋប្បវេណី ( ≠ ការទទួលខុសត្រូវព្រហ្មទណ្ឌ )

- ប្រភពនៃកាតព្វកិច្ច និងសិទ្ធិលើបំណុល
- គោលបំណងចម្បង
  - ការជួយសង្គ្រោះជនរងគ្រោះ
- លក្ខខណ្ឌ(មាត្រា ៧៤៣ កថាខណ្ឌទី ១)
  - ① កំហុសចេតនា ឬ កំហុសអចេតនា
  - ② ការបំពានផលប្រយោជន៍ ឬសិទ្ធិអ្នកដទៃ, ③ ភាពផ្ទុយច្បាប់
  - ④ ការកើតឡើងការខូចខាត, ⑤ ទំនាក់ទំនងហេតុ និងផល
- អានុភាព(មាត្រា៧៤៣ កថាខណ្ឌទី ១, មាត្រា៧៥៧ កថាខណ្ឌទី ១)
  - ជាគោលការណ៍ គឺសំណងការខូចខាត

# ១.២ គោលការណ៍ទទួលខុសត្រូវចំពោះកំហុស

- គ្មានកំហុស គ្មានការទទួលខុសត្រូវ
  - បើគ្រាន់តែមាន "ការបំពានសិទ្ធិរបស់ជនរងគ្រោះដោយសារអំពើរបស់អ្នកដទៃ" នោះ សិទ្ធិទាមទារសំណងការខូចខាតដោយមូលហេតុអំពើអនីត្យានុកូល មិនកើតឡើងទេ។
  - នៅក្នុងករណីសិក្សាទី ១ B គឺជាម្ចាស់សហគ្រាសដែលទទួលការអនុញ្ញាតពីអាជ្ញាធរ ហើយមិនដែលបង្កបញ្ហាទេ ហើយ Y បញ្ជាក់ពីបញ្ហានេះហើយទើបពឹងពាក់ឲ្យចាត់ចែងសំរាម តើករណីនេះអំពើអនីត្យានុកូលកើតឡើងចំពោះ Y ដែរ ឬទេ?
- ករណីលើកលែង
  - ការទទួលខុសត្រូវរបស់និយោជក (មាត្រា ៧៤៧ កថាខណ្ឌទី ១), ការទទួលខុសត្រូវចំពោះសំណង់ដែលជាប់នឹងដី (មាត្រា ៧៥៣ កថាខណ្ឌទី ១)

# ២ ការបំពានសិទ្ធិ និងភាពផ្ទុយច្បាប់

# ២.១ ការបំពានសិទ្ធិ ឬ ផលប្រយោជន៍

- គោលគំនិតដែលយកការបំពានសិទ្ធិ ធ្វើជាល័ក្ខខ័ណ្ឌ
- គោលគំនិតដែលយកការបំពានផលប្រយោជន៍ធ្វើជាល័ក្ខខ័ណ្ឌ (ករណីសិក្សាទី ២)
  - ម៉ាក (Brand) គឺជា "សិទ្ធិ" ដែរឬទេ?

# ២.២ ប្រភេទនៃសិទ្ធិ ឬផលប្រយោជន៍

- សិទ្ធិប្រត្យក្ស
- ផលប្រយោជន៍បុគ្គល(←→ផលប្រយោជន៍ទ្រព្យសម្បត្តិ)
  - អាយុជីវិត(មាត្រា ៧៦០) · រូបរាងកាយ(មាត្រា ៧៦១)
  - សិទ្ធិទាក់ទងនឹងឋានៈ (ករណីសិក្សាទី ៣)
  - កេរ្តិ៍ឈ្មោះ(មាត្រា ៧៦២)
- សិទ្ធិលើបំណុល

# ២.៣ សិទ្ធិទាក់ទងនឹងឋានៈ

- ការពិចារណាទៅលើករណីសិក្សាទី ៣
  - ការប្រឆាំងរបស់ Y ដែលត្រូវបានព្យាករ
  - តើ X និងកូនរបស់ A គឺ Z អាចទាមទារសំណងការខូចខាតចំពោះ Y ដោយផ្អែកលើអំពើអនីត្យានុកូលបានដែរ ឬទេ?

# ២.៤ ភាពផ្ទុយច្បាប់

① ប្រភេទផលប្រយោជន៍ដែលត្រូវបានបំពាន

- □សិទ្ធិប្រត្យក្ស
- □ផលប្រយោជន៍បុគ្គល
- □សិទ្ធិលើបំណុល

② ស្ថានភាពនៃសកម្មភាពបំពាន

- □បំពានបញ្ញត្តិព្រហ្មទណ្ឌ
- □បំពានបញ្ញត្តិត្រួតពិនិត្យ
- □បំពានសណ្តាប់ធ្នាប់សាធារណៈ



## ២.៥ ការអនុវត្តសិទ្ធិស្របច្បាប់ និង អំពើអនីត្យានុកូល

- ការរារាំងជីវភាព(ករណីសិក្សាទី ៤)
  - សកម្មភាពដាក់ឲ្យដំណើរការរថភ្លើងរបស់ក្រុមហ៊ុនផ្លូវដែក Y គឺជាសកម្មភាពស្របច្បាប់ និងមានប្រយោជន៍សម្រាប់សង្គម ប៉ុន្តែតើករណីនេះគួរតែឲ្យទទួលខុសត្រូវលើអំពើអនីត្យានុកូលដែរឬទេ?

→ទោះបីជាការអនុវត្តសិទ្ធិស្របច្បាប់ក៏ដោយ ប្រសិនបើហួសពីទំហំសមស្របមួយ នោះការទទួលខុសត្រូវអំពើអនីត្យានុកូលនឹងកើតឡើង។

- វិវាទទាក់ទងនឹងសិទ្ធិទទួលបានពន្លឺថ្ងៃ(ករណីសិក្សាទី ៥)

# ៣ កំហុស

# ៣.១ កំហុសចេតនា

- មាត្រា ៧៤២ កថាខណ្ឌទី ១
  ① ការព្យាករជាមុនអំពីការកើតឡើងនូវលទ្ធផល
  ② ការគិតថាទោះបីជាលទ្ធផលបែបនោះកើតឡើងក៏ដោយ ក៏គ្មានមធ្យោបាយដែរ
    - មិនទាមទារឲ្យមានការគិតថាចង់បង្កើតលទ្ធផលនោះទេ (ករណីសិក្សាទី ៦ )។

# ៣.២ កំហុសអចេតនា

- មាត្រា ៧៤២ កថាខណ្ឌទី ២
  1. បំពានករណីយកិច្ចព្យាករទុកជាមុននូវលទ្ធផល
  2. បំពានករណីយកិច្ចបញ្ចៀសលទ្ធផល
     - មិនមែនឲ្យតែមានស្ថានភាពមិនប្រុងប្រយ័ត្ន សុទ្ធតែចាត់ទុកថាជាកំហុសអចេតនានោះទេ(ករណីសិក្សា ៧.១)។
     - គំនិតសត្យានុម័តដែលជាការបំពានករណីយកិច្ចធ្វើសកម្មភាពជាកំណត់ (ករណីសិក្សា ៧.២)
     - អត្ថិភាពនៃលទ្ធភាពព្យាករទុកជាមុន និងលទ្ធភាពបញ្ចៀសលទ្ធផល ដោយពិចារណាលើការបំពានករណីយកិច្ចនីមួយៗ
     - ខ្លឹមសារជាក់លាក់នៃករណីយកិច្ច ចាំបាច់ត្រូវធ្វើការកំណត់ខាងភាគីជនរងគ្រោះ

# ៣.៣ កំហុសអចេតនា (ត)

| | គ្មានការបំពានករណីយកិច្ចព្យាករទុកជាមុននូវលទ្ធផល | មានការបំពានករណីយកិច្ចព្យាករទុកជាមុននូវលទ្ធផល |
|---|---|---|
| គ្មានការបំពានករណីយកិច្ចបញ្ចៀសលទ្ធផល | × | × |
| មានការបំពានករណីយកិច្ចបញ្ចៀសលទ្ធផល | — | ○ |

# ៣.៤ ករណីយកិច្ចព្យាករជាមុន និងបញ្ចៀសលទ្ធផល




កម្រិតនៃករណីយកិច្ច និងទំហំនៃបង្កើតការបំពានករណីយកិច្ច

## ៣.៥ មូលដ្ឋាននៃការវិនិច្ឆ័យអំពីករណីយកិច្ចព្យាករទុកជាមុន និងករណីយកិច្ចបញ្ចៀស

- តើត្រូវយកសមត្ថភាពនរណា ធ្វើជាមូលដ្ឋាន?

 →បុគ្គលដែលមានឋានៈនៃការងារ ឬបទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើ

 (មាត្រា ៧៤២ កថា. ២) ≠ អ្នកធ្វើអំពើខ្លួនឯង

- តើត្រូវយកសមត្ថភាពនៅពេលណា ធ្វើជាមូលដ្ឋាន?

 →ពេលធ្វើសកម្មភាព

# ៣.៦ កំហុសអចេតនា និង ភាពផ្ទុយច្បាប់

- មានកំហុសអចេតនា
  - មានការបំពានករណីយកិច្ចព្យាករទុកជាមុននូវលទ្ធផល
  - មានការបំពានករណីយកិច្ចបញ្ចៀសនូវលទ្ធផល

  ←មានសកម្មភាពបំពានបញ្ញត្តិដែលភ្ជាប់ករណីយកិច្ចព្យាករទុកជាមុន និងបញ្ចៀសលទ្ធផល (＝ខុសច្បាប់)
- អាចគិតថា

  មានកំហុសអចេតនា ≒ មានភាពផ្ទុយច្បាប់

# ៤ ការកើតឡើងនៃការខូចខាត

# ៤.១ គោលគំនិតនៃការខូចខាត

- ទស្សនៈនៃការប្រៀបធៀបស្ថានភាពទ្រព្យសម្បត្តិ(មាត្រា ៧៥៨-១)
  - ភាពខុសគ្នារវាងស្ថានភាពទ្រព្យសម្បត្តិដែលជនរងគ្រោះនឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និងស្ថានភាពទ្រព្យសម្បត្តិដែលជនរងគ្រោះមានដោយសារមានអំពើអនីត្យានុកូល គឺជាការខូចខាត។

  ។)ការកើតឡើង ឬមិនកើតឡើងនៃអំពើអនីត្យានុកូល ក្នុងករណីចតរថយន្តនៅលើដីទំនេររបស់អ្នកដទៃមួយរយៈ។

  - លម្អិត នឹងសិក្សានៅក្នុងមេរៀនអំពើអនីត្យានុកូល (ទ្រឹស្តីនៃការខូចខាត)

# ៥ ទំនាក់ទំនងហេតុ និងផល

# ៥.១ ទំនាក់ទំនងហេតុ និងផល នៃអង្គហេតុ

- អត្ថន័យនៃទំនាក់ទំនងហេតុ និងផល នៃអង្គហេតុ
  - តើអាចទទួលស្គាល់ទំនាក់ទំនងរវាងសកម្មភាពបំពាន និងលទ្ធផលដែលកើតចំពោះជនរងគ្រោះថា "បើគ្មានរឿងនោះទេ រឿងនេះក៏គ្មានដែរ" ដែរ ឬទេ ?

- ករណីនីមួយៗនៃករណីសិក្សាទី ៨ តើអាចទទួលស្គាល់ទំនាក់ទំនងហេតុ និងផលនៃអង្គហេតុ រវាងមរណភាពរបស់ X និងសកម្មភាពរបស់ Y បានដែរ ឬទេ ?

# ៥.២ ការបញ្ជាក់ភស្តុតាងអំពីទំនាក់ទំនងហេតុ និងផល នៃអគ្គហេតុ

- ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង
  - គឺដើមបណ្តឹង (ជនរងគ្រោះ)(មាត្រា ៧៤៣ កថា. ៣)
  - ករណីគ្រោះថ្នាក់ដោយសារការព្យាបាល ឬ គ្រោះថ្នាក់ដែលកើតឡើងពីការបំពុលបរិយាកាសសាធារណៈ ឱសថពេទ្យ ឬអាហារ មានការលំបាកក្នុងការបញ្ជាក់ភស្តុតាងអំពីទំនាក់ទំនងហេតុ និងផល
  - នៅពេលបកស្រាយច្បាប់ ចាំបាច់បកស្រាយដើម្បីកុំឲ្យមានការបំពានឱកាសជួយសង្គ្រោះជនរងគ្រោះ ដោយមិនត្រឹមត្រូវ

- កម្រិតនៃការបញ្ជាក់ភស្តុតាង
  - ការបង្ហាញអំពីភាពដែលអាចកើតមានដែលមានកម្រិតខ្ពស់ ≠ ការបង្ហាញអំពីទំនាក់ទំនងហេតុផលបែបវិទ្យាសាស្ត្រធម្មជាតិដែលនឹងត្រូវកើតឡើង១00%

# ៦   សំណួរ និង ចម្លើយ

# សូមអរគុណ

International Cooperation Department

សិក្ខាសាលានៅកម្ពុជា ខែ មិនា ឆ្នាំ ២០១៤

# អំពើអនីត្យានុក្ល

## (ទ្រឹស្តីនៃការខូចខាត)

ថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០១៤

ក្រសួងយុត្តិធម៌ ការិយាល័យស្រាវជ្រាវកិច្ចការរួមនីតិកម្ម ផ្នែកទំនាក់ទំនងអន្តរជាតិ សាស្ត្រាចារ្យ ៖ ម៉ូរិ តូម៉ូយ៉ា

# ទិដ្ឋភាពទូទៅនៃមេរៀន

1. សំណងនៃការខូចខាត
2. ការខូចខាតសកម្ម
3. ការបាត់បង់អកម្ម
4. សំណងជម្ងឺចិត្ត
5. សំណួរ និង ចម្លើយ

# 1 សំណងនៃការខូចខាត

# 1－1　អានុភាពនៃអំពើអនីត្យានុកូល

- សំណងជាប្រាក់(743-1, 757-1)

- ការធ្វើបដិទាន ឬ ការហាមឃាត់មិនឲ្យធ្វើអំពើណាមួយ(757-2)

- (ករណីការបរិហារកេរ្តិ៍) វិធានការស្តារកិត្តិយសឡើងវិញ(757-3)

## 1－2 ទ្រឹស្តីនៃការប្រៀបធៀបស្ថានភាពទ្រព្យសម្បត្តិ

- ទ្រឹស្តីនៃការប្រៀបធៀបស្ថានភាពទ្រព្យសម្បត្តិ (មាត្រា ៧៥៨-១)
  - ភាពខុសគ្នារវាងស្ថានភាពទ្រព្យសម្បត្តិដែលជនរងគ្រោះនឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និងស្ថានភាពទ្រព្យសម្បត្តិដែលជនរងគ្រោះមានដោយសារមានអំពើអនីត្យានុកូល គឺជាការខូចខាត។
- ការទទួលខុសត្រូវក្នុងការបញ្ជាក់បង្ហាញ គឺជាបន្ទុករបស់ដើមចោទ (743-3)
- **វិធីគណនាដោយបូកសរុបដោយឡែកៗ**
  - បែងចែកប្រភេទនៃការខូចខាត
    Ex. សោហ៊ុយពេទ្យ, សោហ៊ុយធ្វើដំណើរ, សោហ៊ុយជួសជុល
  - គណនាចំនួនទឹកប្រាក់នៃការខូចខាតនីមួយៗ
  - បូកសរុបចំនួនទឹកប្រាក់នៃការខូចខាតទាំងអស់

# 1－3 ការបែងចែកប្រភេទនៃការខូចខាត

- ការខូចខាតទ្រព្យសម្បត្តិ＝ ការបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ
  - ការខូចខាតសកម្ម→កថាខណ្ឌទី 2

    ការខូចខាតដែលជនរងគ្រោះបាត់បង់ទ្រព្យសម្បត្តិដែលខ្លួនមាន
  - ការខូចខាតអកម្ម→ កថាខណ្ឌទី3

    ការខូចខាតដែលជនរងគ្រោះមិនអាចទទួលបាននូវប្រយោជន៍(ប្រយោជន៍ដែលបាត់បង់) ដែលខ្លួនអាចនឹងទទួលបាននាពេលអនាគត
- ការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ （744-1）＝ ការខូចខាតក្រៅពីការខូចខាតទ្រព្យសម្បត្តិ
  - សំណងជម្ងឺចិត្ត→កថាខណ្ឌទី4

# 2 ការខូចខាតសកម្ម

# 2－1 ការបាក់បែកវត្ថុ

【ករណីសិក្សា1⑤】

- ករណីមិនអាចជួសជុលបាន(759)
  - ទឹកប្រាក់ស្មើនឹងតម្លៃសម្រាប់ទិញវត្ថុប្រភេទដូចគ្នា គុណភាពដូចគ្នា នៅលើទីផ្សារ
- ករណីអាចជួសជុលបាន(759)
  - ទឹកប្រាក់ស្មើនឹងសោហ៊ុយជួសជុល
  - បើជាវត្ថុដែលជនរងគ្រោះប្រើប្រាស់ គឺទឹកប្រាក់ស្មើនឹងករណីជួលវត្ថុនោះជំនួស
  - ករណីទិញថ្មីចំណាចតិចជាងជួសជុស នោះអនុវត្តដូចករណីមិនអាចជួសជុលបានដែរ

## 2－2 ការបំពានលើជីវិត· ការបំពានលើរូបកាយ

- សោហ៊ុយពេទ្យ(760-1･2, 761)
  - សោហ៊ុយព្យាបាល→ ករណីសិក្សាទី1①
  - សោហ៊ុយចំណាយសម្រាកនៅមន្ទីរពេទ្យ
  - សោហ៊ុយធ្វើដំណើរទៅមកមន្ទីរពេទ្យ→ ករណីសិក្សាទី1③

- (ករណីបំពានលើជីវិត)សោហ៊ុយធ្វើបុណ្យសពជាដើម (760-2)

→ ករណីសិក្សាទី 1⑦

# 3 ការខូចខាតអកម្ម

# 3－1　ប្រយោជន៍ដែលបាត់បង់ដោយសារមរណភាព

【 ករណីសិក្សាទី1⑧】760-1

- ចំណុចពិភាក្សាគោល: សន្តតិកម្មចំពោះសិទ្ធិទាមទារសំណងការខូចខាតជាទ្រព្យសម្បត្តិ
- អាចទាមទារ ដោយយកចំនួនប្រាក់ចំណូលដែលទទួលស្គាល់ថាជនរងគ្រោះអាចទទួលបានក្នុងអំឡុងពេលដែលជនរងគ្រោះអាចធ្វើការបាន បើគាត់មិនស្លាប់ ដកសោហ៊ុយជីវភាពដែលនឹងត្រូវចំណាយ រួច ដកការប្រាក់ពាក់កណ្តាលកាលទៅតាមចំនួនឆ្នាំដែលអាចធ្វើការបាន។
- ចំណូលមូលដ្ឋាន A×（1－អត្រាបន្ថយសោហ៊ុយជីវភាព c）×លទ្ធផលក្រោយការគណនាតាមរូបមន្តលេបនីស(Leibniz) L

## 3–1–1 ប្រាក់ចំណូលជាមូលដ្ឋាន និង ការបន្ថយសោហ៊ុយជីវភាព

- ប្រាក់ចំណូលជាមូលដ្ឋានក្នុងមួយឆ្នាំរបស់ជនរងគ្រោះ (A)
  - ករណីជនរងគ្រោះជា បុគ្គលមានប្រាក់បៀវត្ស នោះភាគច្រើន ចំណូលមូលដ្ឋានគឺស្ថានភាពនៃប្រាក់ចំណូលមូលដ្ឋាននៅមុនអំពើអនីត្យានុកូល
- ការបន្ថយសោហ៊ុយជីវភាព (c)
  - ការដកចំណាយសម្រាប់ជីវភាពដើម្បីទទួលប្រាក់ចំណូលចាំបាច់នៅពេលនៅរស់ ក្នុងករណីជនរងគ្រោះស្លាប់
  - តាងCជាអត្រាសោហ៊ុយជីវភាព នៅក្នុងប្រាក់ចំណូលមូលដ្ឋាន
  - អត្រាCខាងលើខុសគ្នាទៅតាមស្ថានភាពជីវភាពរបស់ជនរងគ្រោះ, ចំនួន ឬ អត្ថិភាព ឬ នត្ថិភាពនៃអ្នកទទួលជីវព្រឹត្តិជាដើម

# 3－1－2 ចំនួនឆ្នាំដែលអាចធ្វើការងារបាន

- ចំនួនឆ្នាំដែលអាចធ្វើការងារបាន
  - អំឡុងពេលដែលជនរងគ្រោះអាចធ្វើការបានប្រសិនបើនៅរស់
- ភាពចាំបាច់នៃការបន្ថយការប្រាក់ពាក់កណ្តាលកាល
  - ផលប្រយោជន៍ដែលបាត់បង់ គឺជាការយកប្រយោជន៍ដែលត្រូវទទួលបានក្នុងរយៈពេលវែងនាពេលអនាគត ផ្តល់ឲ្យក្នុងពេលបច្ចុប្បន្នតែម្តង
  - ចាំបាច់ត្រូវមានការដកការប្រាក់ ដើម្បីកុំឲ្យមានការទទួលបានចំណេកការប្រាក់ខ្ពស់ហួសហេតុ

# 3－1－3 ការបន្ថយការប្រាក់ពាក់កណ្ដាលកាល

Ex. ប្រសិនបើបច្ចុប្បន្នទទួលបានប្រាក់ ៤ម៉ឺនដុល្លារដែលជាចំណូលដែលនឹងទទួលបាននៅ១ឆ្នាំក្រោយ តើចំនួននោះត្រូវជាប៉ុន្មាន? អត្រានៃការប្រាក់ពាក់កណ្ដាលកាលគឺ ៥%។ តើចំនួន ៤ម៉ឺន$ នៅ ២, ៣ ឆ្នាំក្រោយ ត្រូវជាប៉ុន្មាន?

→4ម៉ឺនដុល្លារ $\times \frac{1}{1.05}$

→4ម៉ឺនដុល្លារ $\times \frac{1}{1.05} \times \frac{1}{1.05}$

→4ម៉ឺនដុល្លារ $\times \frac{1}{1.05} \times \frac{1}{1.05} \times \frac{1}{1.05}$

# 3－1－4 ការបន្ថយការប្រាក់ពាក់កណ្ដាលកាល(ត)

Ex. (ត)

- តម្លៃបច្ចុប្បន្ននៃចំណូលដែលអ្នកធ្វើការអាចទទួលបានក្នុងរយៈពេល ៣ឆ្នាំ (៤ម៉ឺន$/ឆ្នាំ) អាចទាមទារបានដូចខាងក្រោម

$$4\text{ ម៉ឺន\$} \times \left(\frac{1}{1.05} + \frac{1}{1.05} \times \frac{1}{1.05} + \frac{1}{1.05} \times \frac{1}{1.05} \times \frac{1}{1.05}\right)$$

- ករណីគណនាប្រយោជន៍ដែលបាត់បង់ គេពិចារណាទៅលើការបន្ថយសោហ៊ុយជីវភាព ហេតុនេះការគណនា គឺដូចខាងក្រោម

$$4\text{ ម៉ឺន\$} \times (1-c) \times \left(\frac{1}{1.05} + \frac{1}{1.05} \times \frac{1}{1.05} + \frac{1}{1.05} \times \frac{1}{1.05} \times \frac{1}{1.05}\right)$$

# 3－1－5 ការបន្ថយការប្រាក់ពាក់កណ្តាលកាល(ត២)

- ការគណនានៅក្នុងប្រអប់ពណ៌នៃ slide លេខ១៣ គឺកំណត់តាមរយៈពេលដែលអាចធ្វើការងារបាន ＝ លទ្ធផលក្រោយការគណនាតាមរូបមន្តលេបនីស(ចំនួនទាក់ទងទៅនឹងការបន្ថយការប្រាក់ពាក់កណ្តាលកាលទៅតាមចំនួនឆ្នាំអាចធ្វើការបាន＝L)
- សំខាន់ ៖ អត្រាការប្រាក់ពាក់កណ្តាលការ គឺអាស្រ័យលើការពិចារណារបស់ភាគីកម្ពុជា (៥%នៅក្នុងឧទាហរណ៍ខាងលើ គឺជាតួលេខបណ្តោះអាសន្ន)
- ប្រាក់ចំណូលមូលដ្ឋាន A×(1－អត្រាការប្រាក់ដោយដកសោហ៊ុយសម្រាប់ជីវភាពប្រចាំថ្ងៃc)× លទ្ធផលក្រោយការគណនាតាមរូបមន្តលេបនីស L

## 3－2 ប្រយោជន៍ដែលបាត់បង់ដោយផ្អែកលើផលវិបាកដែលបន្សល់ក្រោយការព្យាបាល

- អត្រានៃការបាត់បង់សមត្ថភាពធ្វើការ (p)
  - ធ្វើការវិនិច្ឆយទទួលស្គាល់ថា តើមានការធ្លាក់ចុះនៃកម្រិតសមត្ថភាពធ្វើការរបស់ជនរងគ្រោះ ទៅតាមផ្អែក និង កម្រិតនៃផលវិបាកដែលបន្សល់ក្រោយការព្យាបាលដែរ ឬទេ។
- វិធីគណនាប្រយោជន៍ដែលបានបាត់បង់
  - ប្រាក់ចំណូលមូលដ្ឋានA×អត្រានៃការបាត់បង់សមត្ថភាពធ្វើការp× លទ្ធផលក្រោយការគណនាតាមរូបមន្តលេបនីស L ទាក់ទងទៅនឹងការបន្ថយការប្រាក់ពាក់កណ្តាលកាលទៅតាមចំនួនឆ្នាំនៃអំឡុងពេលបាត់បង់សមត្ថភាពធ្វើការ
  - ករណីសិក្សា1④

# 3－3　ការខូចខាតដោយសារការសម្រាកពីការងារ

- និយមន័យ
  - ការបាត់បង់ប្រាក់ចំណូល ដែលកើតឡើងពីការសម្រាកពីការងារដោយសារ មានរបួស និង ការព្យាបាល ឬ មិនអាចផ្លាស់ទីបានដូចធម្មតា នៅក្នុងអំឡុងពេលព្យាបាលរបួសដែលទទួលដោយអំពើអនីត្យានុកូល រហូតដល់ស្ថានភាពជម្ងឺមានលំនឹង【 ករណីសិក្សា1②】
  - ស្ថានភាពជម្ងឺដែលមានលំនឹង＝នៅពេលដែលមិនអាចរំពឹងបានថាលទ្ធផលនៃការព្យាបាលរបួសអាចជាសះស្បើយ ហើយស្ថានភាព ជម្ងឺនៅបន្តមានរហូតដល់ដំណាក់ចុងក្រោយ
- វិធីគណនា

ប្រាក់ចំណូលប្រចាំថ្ងៃនៅមុនពេលមានអំពើអនីត្យានុកូល(ប្រាក់ចំណូលមូលដ្ឋាន)×ចំនួនថ្ងៃឈប់សម្រាកពីការងារចាប់ពីពេលមានអំពើអនីត្យានុកូល រហូតដល់ពេលស្ថានភាពជម្ងឺមានលំនឹង－ការចំណាយក្នុងករណីដែលត្រូវចំណាយមួយផ្នែកនៃប្រាក់ឈ្នួលជាដើម ក្នុងអំឡុងពេលសម្រាកពីការងារ

# 4 សំណងជម្ងឺចិត្ត

# 4－1　សំណងជម្ងឺចិត្ត

- មូលដ្ឋាននៃការគណនា
  - ធាតុផ្សំដែលត្រូវពិចារណា (758-2)
    - កម្រិតនៃកំហុសនៃអំពើបំពាន
    - ប្រភេទ និង កម្រិតនៃការខូចខាត
    - សកម្មភាពរបស់អ្នកប្រព្រឹត្តអំពើបំពាន នៅក្រោយអំពើបំពាន
  - វិធីគណនាគឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម

→អាចមានតួនាទីបំពេញការខូចខាតជាទ្រព្យសម្បត្តិ

# 4－2－1 បណ្តឹងទាក់ទងនឹងគ្រោះថ្នាក់ចរាចរណ៍

- ករណីមរណភាព(760-1, 3)→ ករណីសិក្សា1⑨
  - ចំណុចពិភាក្សាគោល: សន្តតិកម្មចំពោះសិទ្ធិទាមទារសំណងជម្ងឺចិត្តតាមមាត្រា 760-1
  - ការបែងចែកប្រភេទទៅតាមលក្ខណៈរបស់ជនរងគ្រោះ
    ~, មេគ្រួសារ, ម្តាយ, សហព័ទ្ធ, ផ្សេងៗ
  - ការបន្ថែម ឬ បន្ថយដោយផ្អែកលើធាតុផ្សំទាំងឡាយនៃមាត្រា758-2
  - និន្នាការនៃការកំណត់ចំនួនទឹកប្រាក់ (ចំនួនទឹកប្រាក់ត្រូវបានពិចារណាផ្អែកលើមូលដ្ឋាននៃប្រាក់សរុបរួម ដោយបញ្ចូលទាំងប្រាក់ជម្ងឺចិត្តនៃញាតិលោហិតជាកំណត់ ក្រោយពេលជនរងគ្រោះទទួលមរណភាព)

# 4－2－2 បណ្ដឹងទាក់ទងនឹងគ្រោះថ្នាក់ចរាចរណ៍(ត)

- ផលវិបាកបន្សល់ក្រោយការព្យាបាល(761)→ករណីសិក្សា1⑥
  - សំណងជម្ងឺចិត្តដោយសារការចូលពេទ្យ(រហូតដល់ស្ថានភាពជម្ងឺមានលំនឹង)

    ~គណនាដោយយករយៈពេលសម្រាកនៅមន្ទីពេទ្យជាមូលដ្ឋាន
  - សំណងជម្ងឺចិត្តដោយសារផលវិបាកបន្សល់ក្រោយការព្យាបាល (ក្រោយស្ថានភាពជម្ងឺមានលំនឹង )

    ~ គណនាដោយយកកម្រិត និង ខ្លឹមសារនៃផលវិបាកបន្សល់ក្រោយការព្យាបាលជាមូលដ្ឋាន
  - ធាតុផ្សំដែលត្រូវពិចារណា មានដូចជា ដំណើរការនៃការព្យាបាល, ភាពមិនងាយស្រួលជាក់ស្ដែងចំពោះការងារ និង ជីវភាពរបស់ជនរងគ្រោះ
  - សំណងជម្ងឺចិត្តនីមួយៗ ក៏ជានិន្នាការនៃការកំណត់ចំនួនទឹកប្រាក់ដែរ

# 4－2－3　ករណីផលវិបាកបន្សល់ក្រោយការព្យាបាល និង ប្រភេទនៃការខូចខាត(មួយផ្នែក)

គ្រោះថ្នាក់ចរាចរណ៍ → ស្ថានភាពជម្ងឺមានលំនឹង

| | | |
|---|---|---|
| 【ទំនាក់ទំនងទៅនឹងប្រាក់ចំណូល】 | ការខូចខាតដោយត្រូវសម្រាកពីការងារ | ប្រយោជន៍ដែលបានបាត់បង់ |
| 【សំណងជម្ងឺចិត្ត】 | សំណងជម្ងឺចិត្តដោយសារការចូលពេទ្យ | សំណងជម្ងឺចិត្តដោយសារផលវិបាកដែលបន្សល់ក្រោយការព្យាបាល |

# 4－3－1 បណ្ដឹងលែងលះ

- ករណីសិក្សា 2
- ធាតុផ្សំ(អត្ថន័យនៃអំពើអនីត្យានុកូល)
    1. ការបង្កឲ្យមានហេតុដែលមិនអាចជៀសផុតពីការលែងលះ គឺជាអំពើអនីត្យានុកូល
    2. អំពើអនីត្យានុកូលផ្សេងៗ Ex. អំពើផិត, អំពើហិង្សាក្នុងគ្រួសារ
- ## ការខូចខាត
    1. ការឈឺចាប់ផ្នែកសតិអារម្មណ៍បណ្ដាលមកពីការបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍
    2. ការឈឺចាប់ផ្នែកសតិអារម្មណ៍បណ្ដាលមកពីអំពើអនីត្យានុកូលផ្សេងៗនោះ

# 4－3－2 បណ្ដឹងលែងលះ(ត)

- ចំណុចប្រុងប្រយ័ត្ននៅពេលវិនិច្ឆ័យអំពីការទាមទារដោយផ្អែកលើធាតុផ្សំ 1
  - A) អត្ថិភាព ឬ នត្ថិភាពនៃការបែកបាក់ទំនាក់ទំនងអាពាហ៍ពិពាហ៍
  - B) ការទទួលស្គាល់អំពីទំនួលខុសត្រូវរបស់ភាគីម្ខាងទៀត

  → ទោះបីជា A ត្រូវបានទទួលស្គាល់ក៏ដោយ អាចមានករណីលើកចោលការទាមទារសំណងជម្ងឺចិត្តដោយពិចារណាពីចំណុច B

- ធាតុផ្សំក្នុងការពិចារណាអំពីចំនួនសំណងជម្ងឺចិត្ត
  - កម្រិតនៃទំនួលខុសត្រូវរបស់ភាគីម្ខាងទៀត
  - អំឡុងពេលនៃអាពាហ៍ពិពាហ៍
  - ស្ថានភាពជីវភាពអាពាហ៍ពិពាហ៍ដែលឈានដល់ការបែកបាក់អាពាហ៍ពិពាហ៍
  - ស្ថានភាពនៃសកម្មភាពដែលត្រូវទទួលខុសត្រូវ

# 5 សំណួរ និង ចម្លើយ

# សូមអរគុណ !